# មូលនិធិ «ចល័ត» ឆ្នាំ ២០២៤
# របស់អង្គការសិល្បៈខ្មែរអមតៈ

សិល្បៈខ្មែរអមតៈ

| ព័ត៌មានសំខាន់ៗ | |
|---|---|
| **ឱកាស** | មូលនិធិ «ចល័ត» ឆ្នាំ២០២៤ |
| **រចនាឡើងដើម្បី** | ជួយគាំទ្រដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ |
| **ចំនួនបេក្ខភាពជ័យលាភី** | ២ កន្លែង |
| **រយៈពេលអនុវត្តគម្រោង** | ខែ ឧសភា ដល់ខែ ធ្នូ ឆ្នាំ២០២៤ |
| **ជំនួយគាំទ្រ** | រហូតដល់ ១,០០០ ដុល្លារអាមេរិក |

សិល្បៈខ្មែរអមតៈមានសេចក្ដីរីករាយនឹងប្រកាសផ្ដល់មូលនិធិ «ចល័ត» ចំនួនពីរកន្លែង ដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌។

មូលនិធិ «ចល័ត» នេះ បង្កើតឡើងដើម្បីគាំទ្រដល់សិល្បករ និងអ្នកធ្វើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌គ្រប់ទម្រង់ (ដូចជា៖ ភាពយន្ត សិល្បៈទស្សនីភាព សិល្បៈសូនរូប សហគមន៍អ្នកនិពន្ធជាដើម ។ល។ ដើម្បីអភិវឌ្ឍគំនិត និងចំណេះដឹង កសាងបណ្ដាញ និងជំនាញ តាមរយៈការទៅចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា សន្និសីទ មហោស្រព ការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវ និងកម្មវិធីនិវេសនដ្ឋាន ទាក់ទងទៅនឹងសិល្បៈវប្បធម៌ជាដើម។

ពួកយើងចង់គាំទ្រដល់អ្នកដែលមិនធ្លាប់ទទួលបានឱកាសបែបនេះពីមុនមក។ គោលបំណងរយៈពេលវែងនៃមូលនិធិ «ចល័ត» គឺដើម្បីជួយអភិវឌ្ឍវិស័យសិល្បៈក្នុងប្រទេសកម្ពុជា ដោយផ្ដោតសំខាន់ជាពិសេសទៅលើការផ្លាស់ប្ដូរបទពិសោធន៍ ការកសាងសមត្ថភាពសិល្បករ អ្នកនិពន្ធ និងអ្នកស្រាវជ្រាវវប្បធម៌។

សិល្បៈខ្មែរអមតៈ ប្ដេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានរើសអើងអំពីអាយុ ពិការភាព ជនជាតិដើម អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គម សេដ្ឋកិច្ចឡើយ។ យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសំឡេងតិច ហើយយើងនឹងផ្ដល់ការគាំទ្រ (អាស្រ័យលើតម្រូវការ និងភាពចាំបាច់) ទៅដល់បេក្ខជនដែលបានជ្រើសរើសជាបេក្ខភាពជ័យលាភី។

តាមរយៈសិល្បៈ និងស្មារតីរួបរួមគ្នា យើងជឿជាក់ថា យើងអាចរួមគ្នាជំរុញការផ្លាស់ប្ដូរបែបវិជ្ជមានមួយសម្រាប់ប្រជាជាតិកម្ពុជា។ មូលនិធិ «ចល័ត» ចូលរួមចំណែកក្នុងការបង្កើនឱកាសដល់សហគមន៍សិល្បៈ ដើម្បីបង្កើតគំនិតផ្ដួចផ្ដើម ជំនាញ ការបង្កើតស្នាដៃថ្មី និងការកសាងបណ្ដាញដៃគូ។

## ព័ត៌មានលម្អិត

| អំពីមូលនិធិចល័ត | |
|---|---|
| តើមូលនិធិ «ចល័ត» គឺជាអ្វី? | មូលនិធិ «ចល័ត» គាំទ្របេក្ខជន ទៅចូលរួមក្នុងកម្មវិធីទាក់ទងនឹងសិល្បៈ និងវប្បធម៌ រួមមាន៖ សិក្ខាសាលា ការធ្វើនិវេសនដ្ឋាន វគ្គបណ្តុះបណ្តាល និងការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវនៅក្នុងប្រទេសក្នុងតំបន់អាស៊ី។ តាមរយៈមូលនិធិនេះ បេក្ខជនជ័យលាភីក៏អាចអញ្ជើញអ្នកជំនាញមកពីបណ្តាប្រទេសអាស៊ី មកកាន់ប្រទេសកម្ពុជា ដើម្បីដឹកនាំបណ្តុះបណ្តាល សិក្ខាសាលា ឬសន្និសីទ។ល។<br><br><u>មូលនិធិនេះគាំទ្រ ៤ ប្រភេទ៖</u><br>- ការធ្វើដំណើរ<br>- ការស្នាក់នៅ<br>- ប្រាក់សម្រាប់អាហារប្រចាំថ្ងៃ<br>- តម្លៃចុះឈ្មោះ ឬចំណាយផ្សេងៗ ដែលទាក់ទងនឹងការ ធ្វើដំណើរ |
| តើនរណាអាចស្នើសុំមូលនិធិនេះបាន? | សិល្បករ និងអ្នកធ្វើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌គ្រប់ទម្រង់ (ដូចជា៖ ភាពយន្ត សិល្បៈទស្សនីភាព សិល្បៈសូនរូប សហគមន៍អ្នកនិពន្ធ។ល។) |
| សុពលភាពនៃការដាក់សំណើ | យ៉ាងហោចណាស់ ១ ខែ មុនពេលធ្វើដំណើរ ប៉ុន្តែយើងសូមលើកទឹកចិត្តអ្នកឱ្យដាក់ពាក្យស្នើសុំយូរជាងមួយខែប្រសិនបើអ្នកដឹងពីឱកាសនោះជាមុន។<br><br>ក្នុងករណីដែលពាក្យស្នើសុំត្រូវបានដាក់មកយឺតជាងមួយខែ អ្នកដាក់ពាក្យស្នើសុំត្រូវមានភស្តុតាងសមហេតុសមផល ដើម្បីបញ្ជាក់ ឧ. លិខិតពន្យល់ពីអ្នកអញ្ជើញ ទោះយ៉ាងណាក៏ដោយ យើងមិនធានានូវភាពជោគជ័យនៃការស្នើសុំនេះទេ ព្រោះមានតែគណៈកម្មាធិការប៉ុណ្ណោះដែលមានសិទ្ធិសម្រេច។ |
| រយៈពេលទទួលបានចម្លើយ | រយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលដាក់ពាក្យ |
| រយៈពេលនៃការដាក់ពាក្យ | ចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២៤ |
| ចំនួនបេក្ខជន | **ចំនួន ២ រូប (ផ្តល់ជូនក្នុងខែផ្សេងគ្នា)** |
| ចំនួនប្រាក់ឧបត្ថម្ភ | រហូតដល់ ១,០០០ដុល្លារ (មួយពាន់ដុល្លារ សហរដ្ឋអាមេរិក) |
| ទីតាំងនៃគម្រោង | ប្រទេសក្នុងតំបន់អាស៊ី |

មូលនិធិ «ចល័ត» ផ្តល់សម្រាប់តែអ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa ប៉ុណ្ណោះ។

## ទម្រង់នៃការស្នើសុំ[១]

- អ្នកអាចបំពេញពាក្យស្នើសុំរបស់អ្នកជាភាសាខ្មែរ ឬអង់គ្លេស អាស្រ័យទៅតាមភាពងាយស្រួលរបស់អ្នក។

- អ្នកក៏អាចផ្ញើជាវីដេអូ ឬការថតសំឡេង (ឧទាហរណ៍៖ ជាទម្រង់ mp3) ដោយឆ្លើយតបទៅនឹងសំណួរខ្លះ ឬសំណួរទាំងអស់ក្នុងពាក្យស្នើសុំ។ អ្នកត្រូវធ្វើឱ្យប្រាកដថា អ្នកបានអនុវត្តនូវរាល់លក្ខន្តិកៈដែលតម្រូវ ហើយអ្នកបានបំពេញយ៉ាងពេញលេញ។ សូមប្រើ ប្រាស់មុខងាររាប់ពាក្យ (word count) ជាគោលក្នុងការវាស់វែងរយៈពេលវីដេអូ ឬសំឡេងរបស់អ្នក ដោយ ១០០ពាក្យ អាចប្រហាក់ប្រហែលនឹងការនិយាយ ១នាទី។

- ប្រសិនបើបេក្ខជនជួបការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកទូរស័ព្ទមកអ្នកសម្របសម្រួលគម្រោងមូលនិធិ តាមរយៈទូរស័ព្ទ/តេឡេក្រាមលេខ ០៧៧ ៩៥ ៨៥ ៤៥ ឬអ៊ីមែល tola@cambodianlivingarts.org
- ត្រូវបង្ហាញពី៖
    - ការប្តេជ្ញាចិត្តរបស់អ្នកក្នុងការទៅចូលរួមកម្មវិធី
    - ចំណាប់អារម្មណ៍របស់អ្នកអំពីសារៈសំខាន់នៃកម្មវិធី/ដំណើរការសិក្សាស្រាវជ្រាវ ក្នុងការជួយបន្ថែមគំនិត បទពិសោធន៍ ចំណេះដឹង និងការអភិវឌ្ឍវិស័យសិល្បៈ
    - មានការប្តេជ្ញាចិត្តក្នុងការសរសេររបាយការណ៍សង្ខេបអំពីបទពិសោធន៍ និងចំណេះដឹងដែលអ្នកទទួលបានពីកម្មវិធី
    - ឆន្ទៈក្នុងការរៀបចំជំនួបមួយ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការចូលរួម ជាមួយក្រុម សហគមន៍សិល្បៈ និងក្រុមគោលដៅផ្សេងៗទៀតដែលអ្នកគិតថាទាញប្រយោជន៍ពីការចូលរួមក្នុងជំនួបចែករំលែកនេះ

## ដំណើរការនៃការជ្រើសរើស៖

គណៈកម្មការឯករាជ្យនៃគម្រោងមូលនិធិចល័តនឹងពិនិត្យលើពាក្យស្នើសុំរបស់អ្នក។ បន្ទាប់មកគណៈកម្មការនឹងជូនដំណឹងអំពីលទ្ធផលជ្រើសរើសមកកាន់ក្រុមការងារសម្របសម្រួលមូលនិធិ«ចល័ត» ។ បេក្ខជននឹងទទួលដំណឹងតបវិញក្នុងពេលយ៉ាងយូរបំផុត ១០ ថ្ងៃនៃថ្ងៃធ្វើការ ។

សម្រាប់ព័ត៏មានបន្ថែមអំពីដំណើរការដាក់ពាក្យ សូមទាក់ទងមកអ្នកសម្របសម្រួលតាមរយៈ អ៊ីមែល tola@cambodianlivingarts.org ឬ តាមរយៈទូស័ព្ទលេខ ០៧៧ ៩៥ ៨៥ ៤៥ នៅរៀងរាល់ម៉ោងធ្វើការ។

---

[១] *បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ មិនអាចដាក់ពាក្យស្នើសុំមូលនិធិនេះទេ។*